FARMER NOTES

# ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៣ លេខ ២៥ ខែមិថុនា ឆ្នាំ ២០០៤

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ពូជស្រូវធ្ងន់ "រាំងជ័យ"

ពូជ "រាំងជ័យ" ជាពូជស្រូវកណ្តាល ដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាឆ្នាំ ១៩៩៩។ បច្ចុប្បន្ន ពូជរាំងជ័យ បាននឹងកំពុងពេញនិយមក្នុងចំណោមប្រជាកសិករ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ គុណភាពអង្ករល្អប្រសើរមានភាពថ្លា បាយទន់ល្មម និងឆ្ងាញ់ពិសារថែមទៀតផង។

## លក្ខណៈពិសេសៗរបស់ពូជស្រូវរាំងជ័យ

ពូជរាំងជ័យ ជាពូជស្រូវដែលប្រកាន់រដូវមធ្យម ចាប់ចេញផ្កាពីពាក់កណ្តាលខែវិច្ឆិកា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កម្ពស់ដើមរបស់ពូជរាំងជ័យ ប្រែប្រួលពី ១០៥-១៦៨ ស.ម និងចំនួនដើមបែកផ្តល់ផលគឺចាប់ពី ៥-១០ ដើមក្នុងមួយគុម្ព អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយកួរមានចាប់ពី ១៨៦-៣៣៤ គ្រាប់ និងមានប្រវែងកួរ ១៦-៣០ ស.ម។ ពូជរាំងជ័យ ធន់ទ្រាំមធ្យមទៅនឹងទឹកជំនន់ ប៉ុន្តែមិនសូវធន់ទៅនឹងមមាចត្នោតទេ និងមានទិន្នផលជាមធ្យម ៣,៥ តោនក្នុង ១ ហិកតា នឹងអាចខ្ពស់ដល់ទៅ ៥,៥ តោនក្នុង ១ ហិកតា។

## វិធីសាស្ត្រដាំដុះ

សម្រាប់ស្រូវសន្ទូង បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី ៣០-៤០ គីឡូក្រាម ក្នុងមួយហិកតា ប៉ុន្តែក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និងថែទាំបានល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតា គឺពី ១៥-២០ គីឡូក្រាមប៉ុណ្ណោះ។ ដើម្បីឲ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជមួយគីឡូក្រាមលើផ្ទៃដីថ្នាល ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គីសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អ គួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ ដើម។ សម្រាប់ស្រូវពង្រោះ បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី ៦០ គីឡូក្រាមក្នុងមួយហិកតា។ គួររៀបចំដីឲ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រោះ។ ការភ្ជួររាស់ គួរតែធ្វើឲ្យបាន ២-៣ សារជាការល្អប្រសើរ។ ប្រសិនបើស្រែអាចបញ្ចេញបញ្ចូលទឹកបាន បន្ទាប់ពីស្ទូង ឬព្រោះបាន ២០ ថ្ងៃអាចបញ្ចេញទឹកឲ្យអស់ពីក្នុងស្រែ ២-៤ ថ្ងៃរួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឲ្យស្រូវកាន់តែបែកគុម្ពល្អ។

## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្តាលឲ្យមានការថយចុះ ឬបាត់បង់ក្លិន ឬគុណភាពដទៃទៀតឡើយ។ គួរដាក់ជី ២-៣ ដង ក្នុងមួយវដ្តជីវិតរបស់ស្រូវ។ បាចទ្រាប់បាតមុនពេលស្ទូង ដោយប្រើជីធម្មជាតិពី ៥ តោន



(២០ រទេះ) ក្នុង ១ ហិកតា និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី ១។ បរិមាណជីបាចបំប៉នលើកទីមួយ និងលើកទីពីរ ត្រូវអនុលោមតាមតារាងទី ១ ហើយពេលវេលានៃការបាច ត្រូវអនុលោមតាមតារាងទី ២។



តារាងទី ១

| ក្រុមដី | ស្រូវកណ្ដាល និងស្រូវធ្ងន់ (ស្រូវវស្សា) | | | | | |
|---|---|---|---|---|---|---|
| | បាចទ្រាប់បាតមុនស្ទូង ឬព្រោះ (គ.ក្រ/ហាត) | | | | បំប៉នអ៊ុយរ៉េ (គ.ក្រ/ហាត) | |
| | អ៊ុយរ៉េ ៤៦-០-០ | ដេ អា ប៉េ ១៨-៤៦-០ | ប៉ូតាស្យូ ០-០-៦០ | | លើកទី ១ | លើកទី ២ |
| ដីព្រៃខ្មែរ | ១០ | ២០ | ៤០ | | ២០ | ១០ |
| ដីប្រទះឡាង | ១០ | ៥០ | ២៥ | | ២៥ | ២៥ |
| ដីបាកាន ឬអូររាំង | ២៥ | ២៥ | ២៥ | | ៥០ | ២៥ |
| ដីទួលសំរោង | ២៥ | ៥០ | ០ | | ២៥ | ២៥ |
| ដីគោកត្រប់ | ១០ | ៥០ | ៥០ | | ៤០ | ៣៥ |
| ដីកំពង់សៀម | ៣០ | ០ | ០ | | ៤០ | ៣០ |
| ដីកៀនស្វាយ | ជាដីតាមមាត់ច្រាំងទន្លេ និងជម្រាលពីច្រាំងទន្លេសមស្របសម្រាប់ស្រូវស្រាល | | | | | |
| ដីក្រគរ | ជាដីលិចទឹករយៈពេលយូរ ដែលកសិករធ្វើស្រូវឡើងទឹក ឬប្រដេញទឹក | | | | | |
| ដីក្បាលពោធិ | | | | | | |

## ការប្រមូលផល

- ត្រូវប្រមូលផលស្រូវនៅពេលគ្រាប់ទុំល្អ គឺនៅពេលដែលកួរស្រូវមានគ្រាប់ ចាប់ពីពាក់កណ្ដាលកួរឡើងទៅ មានពណ៌លឿងទុំចាស់ និងគ្រាប់ពេញពាក់កណ្ដាលកួរ ចុះក្រោមមានពណ៌លឿងទុំស្រាល ហើយគ្រាប់ស្ងួតវិញមានពណ៌ស្លាបសេកចាស់។

តារាងទី ២

| ពេលវេលាសាប | បំប៉នលើកទី ១ | បំប៉នលើកទី ២ |
|---|---|---|
| ១-៣១ មិថុនា | ៣០ ថ្ងៃក្រោយស្ទូង | ៨-១២ កញ្ញា |
| ១-១៥ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១៣-១៧ កញ្ញា |
| ១៦-៣០ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១៨-២២ កញ្ញា |

- គេអាចហាលសម្ងួតស្រូវនៅលើកន្ទេល សំណាញ់មុង តង់កៅស៊ូ និងលានស៊ីម៉ង់ត៍ គឺមិនបណ្ដាលឲ្យគុណភាពគ្រាប់ស្រូវ ឬគ្រាប់ស្រូវពូជខុសគ្នាឡើយ។ កម្រាស់គ្រាប់ស្រូវដែលសមស្របសម្រាប់ការហាលសម្ងួត គឺ ២-៣ ស.ម ដែលកម្រាស់គ្រាប់ និងសភាពពន្លឺថ្ងៃគឺជាកត្តាចម្បងក្នុងការកំណត់រយៈពេលហាល និងគុណភាពគ្រាប់ស្រូវ៖
  - ថ្ងៃស្រឡះល្អ ហាលតែ ១ ថ្ងៃ ប៉ុណ្ណោះ ដោយកន្ទះម៉ោងរំម្ដង។
  - ថ្ងៃស្រឡះបង្គួរ ហាលសម្ងួតរយៈពេល ២ ថ្ងៃ ដោយមួយម៉ោងរំម្ដង។
  - ថ្ងៃមិនស្រឡះ គេត្រូវហាលរហូតដល់ ៣ ថ្ងៃ ដោយ ២ ម៉ោង រំម្ដង។





- គ្រាប់ពូជត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងឲ្យជិត រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាច់ដោយឡែកពីគ្រាប់ស្រូវចំណី នៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្ដុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។
- ផលស្រូវដែលប្រមូលបាន ត្រូវទុកដាក់ក្នុងជង្រុកឲ្យបានល្អ ដោយការពារកុំឲ្យសត្វកណ្ដុរ មាន់ ទាស៊ី និងមិនឲ្យទទឹក។

សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្ដោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh
ទូរអក្សរ: ssophany@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh